ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣ ✻ ៧៧

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ០៨០ សជណ ធទឧ

# សេចក្តីជូនដំណឹង
## ស្តីពី ការព្យាករណ៍ស្ថានភាពអាកាសធាតុ នារដូវវស្សាឆ្នាំ ២០១៤

បន្ទាប់ពីបានធ្វើការសង្កេតតាមដាន និងព្យាករណ៍លើស្ថានភាពអាកាសធាតុរួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជន ឱ្យបានជ្រាបអំពីស្ថានភាពអាកាសធាតុនារដូវវស្សាឆ្នាំ ២០១៤ ដូចខាងក្រោម ៖

**១-ធាតុភូតសកល ៖**

- សីតុណ្ហភាពលើផ្ទៃសមុទ្រនៅចំណុចខ្សែអេក្វាទ័រ ពាក់កណ្តាលមហាសមុទ្រប៉ាស៊ីហ្វិក មានស្ថានភាពប្រហាក់ប្រហែលនឹងមធ្យមភាគច្រើនឆ្នាំ ។ដោយឡែកសីតុណ្ហភាពនៅមហាសមុទ្រប៉ាស៊ីហ្វិកខាងលិច មានស្ថានភាពទាបជាងមធ្យមភាគច្រើនឆ្នាំ ( ចាប់ពីខែកក្កដា ដល់ខែតុលា ឆ្នាំ ២០១៤ ) ។
- ការវិភាគប្រៀបធៀបទឹកភ្លៀងរវាងឆ្នាំ ២០១៤ ទៅនឹងមធ្យមភាគច្រើនឆ្នាំ បានបង្ហាញឱ្យឃើញថា កម្រិត និងរបាយទឹកភ្លៀង មាននិន្នាការកើនឡើងខ្ពស់ ជាពិសេសចាប់ពីពាក់កណ្តាលរដូវ រហូតដល់ចុងរដូវវស្សា ។

**២-ស្ថានភាព និងការព្យាករណ៍អាកាសធាតុរដូវវស្សាឆ្នាំ ២០១៤ នៅកម្ពុជា ៖**

- នៅចុងរដូវប្រាំងនេះ ទឹកភ្លៀងនឹងបន្តធ្លាក់រាយប៉ាយក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។ រដូវប្រាំងឆ្នាំ ២០១៤ នឹងបញ្ចប់នៅសប្តាហ៍ទី ២ នៃខែឧសភា ។
- តំបន់មាត់សមុទ្រ និងតំបន់វាលទំនាប រដូវវស្សានឹងចាប់ផ្តើមនៅក្នុងសប្តាហ៍ទី ៣ នៃខែឧសភា ឯតំបន់ខ្ពង់រាប រដូវវស្សានឹងចាប់ផ្តើមនៅក្នុងសប្តាហ៍ទី ៤ នៃខែឧសភា ។
- ចាប់ពីពាក់កណ្តាលខែឧសភា ដល់ខែមិថុនា ទឹកភ្លៀងធ្លាក់រាយប៉ាយក្នុងកម្រិតមធ្យម ( អាចទាបជាងឆ្នាំ ២០១៣ ) ។ **ក្នុងអំឡុងពេលនេះ អាចមានផ្គរ រន្ទះ និងខ្យល់កន្ត្រាក់ កើតឡើងច្រើន** ។
- **កូនរដូវប្រាំង** ៖ អាចនឹងកើតមានក្នុងរយៈពេលខ្លី ( ក្នុងសប្តាហ៍ទី ៣ និងសប្តាហ៍ទី ៤ នៃខែកក្កដា ) នៅតាមបណ្តាខេត្តភាគខាងលិចជួរភ្នំក្រវាញ ដូចជាខេត្តតាកែវ កំពង់ស្ពឺ និងភាគខាងលិចនៃខេត្តកណ្តាល ។
- ចាប់ពីខែកក្កដា ដល់ខែវិច្ឆិកា បរិមាណទឹកភ្លៀងធ្លាក់រាយប៉ាយពីបង្គួរទៅច្រើន ។ កម្រិតទឹកភ្លៀងអាចនឹងធ្លាក់ចុះច្រើនជាងឆ្នាំ ២០១៣ ( ប្រហាក់ប្រហែលនឹងឆ្នាំ ២០១១ ) ។
- រដូវវស្សាឆ្នាំ ២០១៤ នឹងបញ្ចប់នៅសប្តាហ៍ទី ៣ នៃខែវិច្ឆិកា ។
- ក្នុងឆ្នាំ ២០១៤ នេះ ព្យុះដែលកើតឡើងនៅក្នុងសមុទ្រប៉ាស៊ីហ្វិកអាចមានពី ២៤-២៦ ព្យុះ ហើយព្យុះដែលវិលចូលមកក្នុងសមុទ្រចិនខាងត្បូង អាចនឹងមានចំនួនច្រើនជាងឆ្នាំ ២០១៣ ។

ក្រសួងធនធានទឹក និងឧតុនិយម បាន និងកំពុងបន្តតាមដានលើស្ថានភាពអាកាសធាតុជាប់ជាប្រចាំ ហើយនឹងធ្វើសេចក្តីជូនដំណឹងបន្ថែមជាបន្តបន្ទាប់ក្នុងករណីចាំបាច់ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១៤*

**រដ្ឋមន្ត្រី**

**លឹម_គានហោ**


អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ ( ៨៥៥ ២៣.៧២៥ ៩៨៩ / ( ៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh